ការគ្រប់គ្រងអ្នកជម្ងឺដែលមាន
ជម្ងឺរាកស្រួចស្រាវ

នៅមន្ទីរពេទ្យថ្នាក់កណ្តាល ថ្នាក់ខេត្ត និងថ្នាក់ស្រុក និងនៅថ្នាក់មណ្ឌលសុខភាព

និយមន័យករណីគ្លីនិក: រាកមកសុទ្ធតែទឹកធ្ងន់ធ្ងរ (ជាញឹកញាប់ ដូចទឹកបបរ ហើយច្រើនតែមានក្លិនឆ្អាបដូចត្រី) ដោយមានឬគ្មានក្អួត, ដោយមាន ឬគ្មានខ្សោះជាតិទឹកធ្ងន់ធ្ងរ ឬស្លាប់, កើតឡើងចំពោះអ្នកជំងឺអាយុ ៥ឆ្នាំ ឡើងទៅ។

១. កំណត់ពីកម្រិតនៃការខ្សោះជាតិទឹក

ពិនិត្យរកមើល:
- ស្ថានភាពទូទៅ
- ភ្នែក
- មាត់ និងអណ្តាត
- ស្រេកទឹក
- ច្បិចស្បែក

គ្មានខ្សោះជាតិទឹក
- សុខភាពល្អ រវាសរវៃ
- ភ្នែកធម្មតា
- អណ្តាតសើម
- ផឹកធម្មតា មិនស្រេកទឹក
- ច្បិចស្បែក រលាទៅវិញធម្មតា

ខ្សោះជាតិទឹកខ្លះ
- នៅមិនស្ងៀម រញ៉ាំរញ៉ូវ
- ភ្នែកខូង
- អណ្តាតស្ងួត
- ស្រេកទឹក ផឹកត្រហេបត្រហប
- ច្បិចស្បែក រលាទៅវិញយឺតៗ

ខ្សោះជាតិទឹកធ្ងន់ធ្ងរ
- អស់កម្លាំង ឬបាត់ស្មារតី
- ភ្នែកខូងខ្លាំង និងស្ងួត
- ស្ងួតខ្លាំង
- ផឹកតិចតួច ឬមិនអាចផឹកបាន
- ច្បិចស្បែក រលាទៅវិញយឺតៗ ខ្លាំង

២. ព្យាបាលគ្រប់អ្នកជម្ងឺទាំងអស់ជាបន្ទាន់

ការព្យាបាលពីដំបូងដោយប្រើទឹកអូរ៉ាលីត គឺសង្គ្រោះជីវិតអ្នកជម្ងឺដែលមានជម្ងឺអាសន្នរោគ។

គ្មានខ្សោះជាតិទឹក

អ្នកជម្ងឺអាចសម្រាកព្យាបាលនៅផ្ទះ។ ឱ្យអ្នកជម្ងឺផឹកទឹកអូរ៉ាលីតបន្ទាប់ពីរាល់ពេលជុះរាកម្តងៗ ដោយអនុវត្តតាមកាលវិភាគខាងក្រោម:

អាយុ	បរិមាណទឹកអូរ៉ាលីតបន្ទាប់ពីជុះរាកម្តងៗ គិតជា ម.ល	បរិមាណទឹកអូរ៉ាលីតបន្ទាប់ពីជុះរាក ម្តងៗ គិតជាកែវ (២០០ម.ល)	ចំនួនកញ្ចប់អូរ៉ាលីតដែលត្រូវការក្នុងមួយថ្ងៃ
តិចជាង ២៤ខែ	៥០-១០០ម.ល	១/៤-១/២កែវ	១/២កញ្ចប់/ថ្ងៃ
២-៩ឆ្នាំ	១០០-២០០ម.ល	១/២-១កែវ	១កញ្ចប់/ថ្ងៃ
១០ឆ្នាំ ឡើងទៅ	តាមតម្រូវការ	តាមតម្រូវការ	យ៉ាងតិច ២កញ្ចប់/ថ្ងៃ

- ប្រសិនបើអ្នកជម្ងឺក្អួត សូមរង់ចាំ១០នាទី បន្ទាប់មកឱ្យទឹកអូរ៉ាលីតដោយយឺតៗ។
- បន្តផ្តល់ទឹកអូរ៉ាលីត និងជាតិទឹកបន្ថែមទៀតរហូតដល់ឈប់រាក។
- ប្រាប់អ្នកជម្ងឺឱ្យត្រឡប់មកមណ្ឌលសុខភាព ឬមន្ទីរពេទ្យជាបន្ទាន់ ប្រសិនបើមិនធូរស្រាល ឬផឹកមិនបាន។
- ប្រសិនបើអ្នកជម្ងឺរឹតតែឈឺធ្ងន់ឡើង ចូរពិនិត្យមើលម្តងទៀត និងធ្វើការព្យាបាលទៅតាមកម្រិតនៃការខ្សោះជាតិទឹក។

ខ្សោះជាតិទឹកខ្លះ

បន្ទាប់ពីឱ្យអូរ៉ាលីតហើយ សូមបញ្ជូនអ្នកជម្ងឺទៅមន្ទីរពេទ្យបង្អែក

ឱ្យអ្នកជម្ងឺផឹកទឹកអូរ៉ាលីតក្នុងអំឡុង៤ម៉ោងដំបូងដោយអនុវត្តតាមកាលវិភាគដូចខាងក្រោម:

ទម្ងន់	អាយុ	បរិមាណទឹកអូរ៉ាលីតក្នុងអំឡុង៤ម៉ោង ដំបូង
ក្រោម៥គ.ក	ក្រោម៤ខែ	២០០-៤០០ម.ល
៥-៧,៩គ.ក	៤-១១ខែ	៤០០-៦០០ម.ល
៨-១០,៩គ.ក	១២-២៣ខែ	៦០០-៨០០ម.ល
១១-១៥,៩គ.ក	២-៤ឆ្នាំ	៨០០-១២០០ម.ល
១៦-២៩,៩គ.ក	៥-១៥ឆ្នាំ	១២០០-២២០០ម.ល
៣០គក ឡើងទៅ	មនុស្សពេញវ័យ	២២០០-៤០០០ម.ល

សំគាល់:
សូមប្រើអាយុកុមារតែពេលណាដែលអ្នកមិនដឹងពីទម្ងន់។
ប្រសិនបើដឹងទម្ងន់ បរិមាណទឹកអូរ៉ាលីត (ជាម.ល) អាចគណនាដោយគុណទម្ងន់អ្នកជម្ងឺ (ជាគ.ក) នឹង ៧៥។
នៅមន្ទីរពេទ្យបង្អែក សូមផ្តល់ថ្នាំជាតិស័ង្កសី ប្រសិនបើមានយោងទៅតាមពិធីសារណែនាំស្តីពីការប្រើថ្នាំនេះ។

ពិនិត្យឡើងវិញកម្រិតនៃការខ្សោះទឹករបស់អ្នកជម្ងឺបន្ទាប់ពី៤ម៉ោងក្រោយ និងធ្វើការព្យាបាលតាមការគួរ។

ខ្សោះជាតិទឹកធ្ងន់ធ្ងរ

ដាក់សេរ៉ូមឡាក់តាត ១០០មល/គក តាមសរសៃ ចែកសេរ៉ូមដូចខាងក្រោម:

អាយុ	មុនដំបូងឱ្យ ៣០មល/គក ក្នុងអំឡុង:	បន្ទាប់មកឱ្យ៧០មល/គក ក្នុងអំឡុង:
ក្រោម១២ខែ	១ម៉ោង	៥ម៉ោង
លើស១២ខែ និង មនុស្សពេញវ័យ	៣០នាទី	២ម៉ោងកន្លះ

ពិនិត្យមើលអ្នកជម្ងឺ:
- ក្រោយពីបានឱ្យ ៣០ម.ល ដំបូង តាមសរសៃ
- ហើយបន្ទាប់មក រាល់១-២ម៉ោងម្តង
- ប្រសិនបើមិនធូរស្រាល ចូរដាក់ល្បឿនសេរ៉ូម ឱ្យលឿនជាងមុន។

ពិនិត្យមើល៦ម៉ោងក្រោយ (សម្រាប់អ្នកជម្ងឺ អាយុក្រោម ១២ខែ) ឬ ៣ម៉ោងក្រោយ (សម្រាប់អ្នកជម្ងឺអាយុលើស១២ខែ) និងធ្វើការព្យាបាលតាមការគួរ។

ប្រសិនបើអ្នកជំងឺរឹតតែធ្ងន់ធ្ងរ សូមផ្តល់ថ្នាំអង់ទីប៊ីយ៉ូទិក ដូចខាងក្រោម:

អង់ទីប៊ីយ៉ូទិក	កម្រិតប្រើ និង រយៈពេល	កុមារ					មនុស្សពេញវ័យ
		ក្រោម៤ខែ ក្រោម៥គក	៤-១២ខែ ៥-ក្រោម ១០គក	១២ខែ-ក្រោម២ឆ្នាំ ១០-ក្រោម ១៥គក	២ឆ្នាំ-ក្រោម៥ឆ្នាំ ១៥-ក្រោម ២០គក	៥-១៤ឆ្នាំ ២០-៣០គក	
Ampicillin 500mg	25mg/kg/ DOSE ៤ដង/ថ្ងៃ រយៈពេល៣ថ្ងៃ	១/៤គ្រាប់ ៤ដង/ថ្ងៃ រយៈពេល៣ថ្ងៃ	១/២គ្រាប់ ៤ដង/ថ្ងៃ រយៈពេល៣ថ្ងៃ	១/២គ្រាប់ ៤ដង/ថ្ងៃ រយៈពេល៣ថ្ងៃ	១គ្រាប់ ៤ដង/ថ្ងៃ រយៈពេល៣ថ្ងៃ	១គ្រាប់ ៤ដង/ថ្ងៃ រយៈពេល៣ថ្ងៃ	២+១/២គ្រាប់ ៤ដង/ថ្ងៃ រយៈពេល៣ថ្ងៃ
Ciprofloxacin គ្រាប់ 250mg គ្រាប់ 500mg	10-15mg/kg/ DOSE ២ដង/ថ្ងៃ រយៈពេល៣ថ្ងៃ	១/៤នៃគ្រាប់ 250mg ២ដង/ថ្ងៃ រយៈពេល៣ថ្ងៃ	១/២នៃគ្រាប់ 250mg ១/៤នៃគ្រាប់ 500mg ២ដង/ថ្ងៃ រយៈពេល៣ថ្ងៃ	១/២នៃគ្រាប់ 250mg ១/៤នៃគ្រាប់ 500mg ២ដង/ថ្ងៃ រយៈពេល៣ថ្ងៃ	១គ្រាប់ 250mg ១/២នៃគ្រាប់ 500mg ២ដង/ថ្ងៃ រយៈពេល៣ថ្ងៃ	១គ្រាប់ 500mg ២ដង/ថ្ងៃ រយៈពេល៣ថ្ងៃ	១គ្រាប់ 500mg ២ដង/ថ្ងៃ រយៈពេល៣ថ្ងៃ

សូមកុំភ្លេចផ្តល់ថ្នាំជាតិស័ង្កសី យោងទៅតាមពិធីសារណែនាស្តីពីការប្រើប្រាស់ថ្នាំនេះ និងប្រសិនបើមានថ្នាំនេះនៅមន្ទីរពេទ្យ។

ការព្យាបាលពីដំបូងដោយប្រើទឹកអូរ៉ាលីត គឺសង្គ្រោះជីវិតអ្នកជម្ងឺដែលមានជម្ងឺអាសន្នរោគ!

ការព្យាបាលដោយប្រើឱសថអង់ទីប៊ីយ៉ូទិក គួរប្រើសម្រាប់តែអ្នកជម្ងឺធ្ងន់ធ្ងរប៉ុណ្ណោះ!

ប្រសិនបើអ្នកសង្ស័យថាមានជម្ងឺអាសន្នរោគ ចូររាយការណ៍ជាបន្ទាន់ដល់បុគ្គលិកសុខាភិបាលពាក់ព័ន្ធនៅថ្នាក់ជាតិ ខេត្ត និងស្រុក (ដោយប្រើទូរស័ព្ទ)

ក្នុងនាមអ្នកជាបុគ្គលិកសុខាភិបាល អ្នកគួរអនុវត្តតាមគោលការណ៍អនាម័យដូចខាងក្រោម:

លាងដៃអ្នកជាមួយសាប៊ូ (ឬផេះ ប្រសិនបើគ្មានសាប៊ូ)
- មុនពេលរៀបចំអាហារ និង
- មុនពេលហូបអាហារ
- ក្រោយពេលប៉ះអ្នកជម្ងឺអាសន្នរោគ

រំងាប់មេរោគសំលៀកបំពាក់អ្នកជម្ងឺ សម្ភារៈផ្សេងៗទៀតរបស់អ្នកជម្ងឺ និងកន្លែងដេក ដូចជាគ្រែ ពូក ដោយ:
- ស្ងោនឹងទឹកក្តៅ
- ដាក់ក្នុងសូលុយស្យុងក្លរីន ឬ
- បោកជាមួយសាប៊ូ និង/ឬ ដាក់ហាលថ្ងៃ

ប្រមូលលាមក និងកំអួតអ្នកជម្ងឺដាក់ក្នុងកន្ត្រេ រួចចាក់ចោលក្នុងបង្គន់ ឬកប់ចោល។ ប្រសិនបើអ្នកជម្ងឺក្អួត ឬបន្ទោបង់ដាក់លើឥដ្ឋ ចូរយកផេះមកចាក់ពីលើ មុននឹងកើបចេញ និងយកទៅចោល។

ក្រសួងសុខាភិបាល

WHO